ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមហាផ្ទៃ

សាលាខេត្តក្រចេះ

លេខ ១៧.....សសរ.ក្រច

# សេចក្តីសម្រេច

## ស្តីពី

## ការបង្កើតក្រុមការងារ កំណត់សួយសារ ក្រួស ខ្សាច់ ខេត្តក្រចេះ

## អភិបាលខេត្តក្រចេះ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកម/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥១២/៤០៥ ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១២ ស្តីពីការតែងតាំងអភិបាលនៃគណៈអភិបាលខេត្តក្រចេះ
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ.បក ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ២១៦ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នា២០០៩ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក
- យោងប្រកាសអន្តរក្រសួងលេខ ០០៦ ប្រក.សហវ ចុះថ្ងៃទី០៤ ខែ មករា ឆ្នាំ២០០១ របស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ស្តីពីការកំណត់ថ្លៃវត្ថុធាតុដើមថ្មសម្ភារសំណង់
- យោងសេចក្តីសម្រេចលេខ១៩៧ សសរ.ធទឧ ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០១៤ របស់រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម និងជាប្រធានគណៈកម្មាធិការគ្រប់គ្រងធនធានខ្សាច់ ស្តីពីការកែសម្រួលសមាសភាព និងការប្រព្រឹត្តទៅរបស់លេខាធិការដ្ឋានគណៈកម្មាធិការគ្រប់គ្រងធនធានខ្សាច់
- យោងកំណត់ហេតុប្រជុំ ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៤ របស់សាលាខេត្ត ស្តីពីការធ្វើអាជីវកម្មបូមក្រួស ខ្សាច់ក្នុងខេត្ត
- យោងតាមការចាំបាច់របស់ខេត្ត ។

## សម្រេច

**ប្រការ ១.-**

បង្កើតក្រុមការងារកំណត់សួយសារ ក្រួស ខ្សាច់ខេត្ត ដែលមានសមាសភាពដូចខាងក្រោម ៖

| | | |
|---|---|---|
| ១-លោក សុខ គីរីរតន៍ | ប្រធានមន្ទីររ៉ែ និងថាមពលខេត្ត | ជាប្រធាន |
| ២-លោក ទូច ហឿន | ប្រធានមន្ទីរ សេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្ត | ជាអនុប្រធាន |

៣-លោក ហេង រត្ន័ម៉ូនីដា ប្រធានមន្ទីរធនធានទឹក និងឧតុនិយមខេត្ត ជាសមាជិក

៤-លោក សៅ សុផល នាយកស្តីទី នៃទីចាត់ការអន្តរវិស័យសាលាខេត្ត ជាសមាជិក

**ប្រការ ២.-**

ក្រុមការងារមានភារកិច្ចដូចតទៅ ៖

- ត្រួតពិនិត្យការងារបច្ចេកទេសដើម្បីកំណត់វាយតម្លៃទំហំអាជីវកម្ម
- កំណត់ស្ទួយសារក្រួស ខ្សាច់
- បំពេញការងារផ្សេងៗទៀត តាមការចាំបាច់របស់ក្រុមការងារ

**ប្រការ ៣.-**

នាយករដ្ឋបាលសាលាខេត្ត ទីចាត់ការទាំង៥ អង្គភាពលទ្ធកម្មចំណុះសាលាខេត្ត មន្ទីរ អង្គភាពពាក់ព័ន្ធជុំវិញខេត្ត អស់លោកដែលមានឈ្មោះក្នុងប្រការ១ មានភារកិច្ចអនុវត្តតាមសេចក្តីសម្រេចនេះ ឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ក្រចេះ ថ្ងៃទី [illegible] ខែ មិនា ឆ្នាំ២០១៥

អភិបាលខេត្ត

សារ ចំរុង

**ចម្លងជូន**
- ក្រសួងមហាផ្ទៃ
- ក្រសួងរ៉ែ និងថាមពល
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងធនធានទឹក និងឧតុនិយម
  "ដើម្បីគោរពជូនជ្រាប"
- ដូចក្នុងប្រការ ៣ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ